# អដ្ឋមូត៌ិ (Aṣṭamŭrti)

អដ្ឋមូត៌ិ មានន័យថា "ការបង្ហាញទម្រង់ទាំងប្រាំបីរបស់ព្រះឥសូរ" ដ្បិត ពាក្យ "អដ្ឋ" ប្រែថា ៨ និង "មូត៌ិ" ប្រែថា ការបង្ហាញ។ ទម្រង់នេះបង្ហាញអំពីគុណលក្ខណៈទាំងប្រាំបីយ៉ាងរបស់ព្រះឥសូរ ដែលរួមមាន គរ៌ ( Śarva) ដី (អ្នកបំផ្លាញ), ភវ (Bhava) ទឹក (ការបង្កើត), រុទ្រ (Rudra) ភ្លើង (អ្នកបណ្តេញអំពើអាក្រក់), ឧគ្រ (Ugra) ខ្យល់ (កាចសាហាវ) , ភីម (Bhīma) លំហ (អស្ចារ្យ), បតុបតិ (Paśupati) ព្រលឹង (ម្ចាស់នៃលោក), ឦគាន (Īśāna) ព្រះអាទិត្យ (លោកបាល) និងមហាទេវ (Mahādeva) ព្រះច័ន្ទ (ដែលជាធំ)។[១] នៅស្រុកឥណ្ឌាដែលជាទីតាំងរីកដុះដាលនៃសាសនាព្រាហ្មណ៍ គេកម្រឃើញមានបដិមានិងរូបចម្លាក់តំណាងឱ្យអដ្ឋមូត៌ិណាស់ ពោល គឺមានតិចតួចបំផុត។ យោងតាមឯកសាររបស់លោក Deglurkar, G.B. រៀបរាប់ឱ្យដឹងថា កាលពីខែកក្កដា ឆ្នាំ ១៩៧៤ នាយកដ្ឋានប្រវត្តិសាស្ត្រវប្បធម៌និងបុរាណវិទ្យានៃសាកលវិទ្យាល័យ Nagpur បានធ្វើកំណាយនៅភូមិមន្ទល (Mandhal) រកឃើញរូបបដិមាចំនួន ៣ ដែលមានមួយក្នុងចំណោមនោះមានរូបធ្វើអំពីថ្មភក់ទំហំ ២៥ x ១៧ x ៩ ស.ម. មានព្រះហស្តពីរនិងព្រះសិរប្រាំបី មានអាយុកាលរវាងស.វ.ទី៣-៥ ដែលគេសន្និដ្ឋានថាគឺជារូបព្រះសិវក្នុងទម្រង់ជា "អដ្ឋមូត៌ិ"។[២] សម័យក្រោយមកគេកម្រឃើញមានចម្លាក់ឬបដិមានៅក្នុងស្រុកឥណ្ឌាឆ្លាក់បង្ហាញរូបអដ្ឋមូត៌ិណាស់។

ដោយឡែក នៅក្នុងអារ្យធម៌ខ្មែរវិញ ពាក្យ "អដ្ឋមូត៌ិ" លេចឡើងដំបូងនៅក្នុងសិលាចារឹកប្រាសាទបាគង (K.826) (រូបលេខ១) រាជ្យព្រះឥន្ទ្រវរ្ម័នទី១ ស.វ.ទី៩ គាថាទី២៥ ដែលរៀបរាប់ថា៖

"ឥលានិលាគ្និចន្ទ្រាគ៌្គ សលិលាកាគយជ្វនះ
រាជវុត្តិវិតេគស្យ សោដ្ឋមូត៌ិទ្ធិបត។

ប្រែថា៖

"ព្រះអង្គទ្រង់បានប្រតិស្ឋានព្រះបដិមាអស្តមូត៌ិរបស់ព្រះឦគ តាមព្រះរាជប្រវេណី និងតាមទម្រង់ផែនពសុធា ខ្យល់ ភ្លើង ព្រះចន្ទ្រ ព្រះអាទិត្យ ទឹក អាកាស និងការបូជាយញ្ញ"។[៣]

តាមទិន្នន័យសិលាចារឹកនេះ គេពុំដឹងប្រាកដថាព្រះបដិមាអដ្ឋមូត៌ិនៅប្រាសាទបាគងនេះជារូបអ្វីឱ្យប្រាកដឡើយ តែគេគ្រាន់សន្និដ្ឋានចំនួនប្រាំបីអាចសំដៅទៅលើប្រាង្គទាំងប្រាំបីនៅក្នុង

---

[១] Bhattacharya 1953: 233-241.

[២] Deglurkar 1982: 786.

[៣] ប្រែសម្រួលដោយ លោក កំ វណ្ណារ៉ា។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

កំពែងទី១របស់ប្រាសាទបាគង[4៤] ដែលសុទ្ធសឹងជាតួប៉មធ្វើអំពីឥដ្ឋ (រូបលេខ២-៣)។

ក្រោយមកទៀត គេតែងប្រទះឃើញពាក្យនេះនៅក្នុងសិលាចារឹកមួយចំនួនក្នុងស.វ.ទី១០ ជាពិសេសសិលាចារឹកក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស.៩៤៤-៩៦៧)។ ជាក់ស្តែងនៅក្នុងសិលាចារឹកប្រាសាទនាគបួស (K.580) រៀបរាប់ថា "ព្រះបាទស្រីរាជេន្ទ្រវរ្ម័ន បានបង្គាប់ឱ្យស្តេងអញព្រះគ្រូបញ្ញាដល់មន្ត្រីឱ្យស្ថាបនាព្រះកម្រតេងអញអដ្ឋមូត្តិនៅស្រុកស្វយម្ភុបុរ និងបានថ្វាយខ្ញុំបម្រើព្រះ" (រូបលេខ៤)។[5៥] ករណីសិលាចារឹកប្រាសាទនាគបួសនេះដូចប្រាសាទបាគងដែរ គឺយើងមិនអាចដឹងបានថាតើព្រះឥសូរក្នុងទម្រង់អដ្ឋមូតិដែលបានរៀបរាប់នេះ សិល្បករបង្ហាញជារូបភាពបែបណាឡើយ។

ងាកថយក្រោយបន្តិចទៅមើលរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ (គ.ស.៧៧០-៨៣៤) វិញ តាមការស្រាវជ្រាវផ្នែកបុរាណវិទ្យាគេធ្លាប់រកឃើញថ្មបញ្ចុះចំនួន៨ដុំ មានរាងកាកបាទបញ្ចុះនៅក្នុងគ្រឹះប្រាសាទអារាមរោងចិន ដែលស្ថិតនៅលើភ្នំគូលែន ខេត្តសៀមរាប និងមានអាយុកាលនៅស.វ.ទី៩ (រូបលេខ៥)។ ថ្មបញ្ចុះរាងកាកបាទនេះ លោក Bruno BRUGUIER, Jean-Baptiste CHEVANCE, Olivier CUNIN យល់ថាជាការបង្ហាញទម្រង់ទាំង៨របស់ព្រះឥសូរ (អដ្ឋមូតិ៌)[6៦] ហើយគំនិតនេះបានយល់ស្របដោយកញ្ញា ផ្លូន ចាន់ដារីយ៉ា ដ្បិតកញ្ញាយល់ថាថ្មបញ្ចុះនេះមានចំនួន៨ដុំ ដាក់ភ្ជាប់គ្នាជាប្រាំបីថ្នាក់ តាំងពីគ្រឹះក្រោមរហូតដល់បាតសិរលិង្គ។[7៧]

សរុបសេចក្តីមក យើងបានដឹងច្បាស់ថាសិល្បករខ្មែរបុរាណបានស្គាល់ច្បាស់អំពីគំនិតនៃអដ្ឋមូតិ៌របស់ព្រាហ្មណ៍សាសនានៅសម័យអង្គរ។ ទោះបីជាយ៉ាងណា យើងពុំដឹងថានៅសម័យមុនអង្គរ តើគេប្រើប្រាស់គំនិតនេះដែរឬអត់ទេ ដ្បិតសិលាចារឹកសម័យមុនអង្គរពុំឃើញមានរៀបរាប់អំពីពាក្យនេះឡើយ។ ប៉ុន្តែ បើយើងគិតអំពីសំណង់ដែលមានរាងប្រាំបីជ្រុងវិញ យើងឃើញមានច្រើនណាស់នៅស.វ.ទី៧ ពោល គឺនៅតំបន់ប្រាសាទសំបូរព្រៃគុកដែលមានរហូតដល់១៥តួប៉ម (រូបលេខ៦) និងជាពិសេសទៀតនោះនៅខាងមុខតួប៉ម N7 នៃក្រុមខាងជើងយើងឃើញមានជើងទម្រមួយរាងប្រាំបីជ្រុងថែមទៀតផង (រូបលេខ៧)។ ក្រៅពីសំណង់ប្រាសាទនិងជើងទម្រ យើងក៏ដឹងច្បាស់ថានៅតំបន់ប្រាសាទសំបូរព្រៃគុកមានជំនឿទៅលើព្រះឥសូរមុតមាំណាស់៕

៤ Alveres 1992: 27-38.

៥ Coedês 1954: 154-155.

៦ Bruno et al 2020: 628.

៧ ផ្លូន ចាន់ដារីយ៉ា ២០២១:៥២។

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

# ឯកសារយោង


**ង៉ួន ចាន់ដារីយ៉ា**

២០២១, *ការសិក្សាអំពីគ្រឿងបញ្ចុះនៅតាមប្រាសាទនាសម័យបុរាណ*, ភ្នំពេញ

**Alveres, S.**

1992, ‘L’iconographie du temple de Bakong de sa foundation au XIIIe siècle, *Histoire de l’art*, N°. 20, Paris

**Bhattacharya, K.**

1953, ‘The Astamurti concept of Shiva in India’, *The Indian Historical Quarter,* No-3,

**Bruno, B. et al**

2020, *Les “marches” d’Angkor, Guide archéologique du Cambodge*, VI, Phnom Penh

**Coedès, G.**

1954, *Inscription du Cambodge*, Tome VI, Hanoi

**Deglurkar, G.B.**

1982, ‘A unique Astamurti image from Mandhal’, *Proceedings of the Indian History Congress,* Vol 43, pp. 786-789




*រូបលេខ១៖ ក្រដាសផ្តាមសិលាចារឹកបាគង K.826 ខេត្តសៀមរាប (ផ្តិតដោយ៖ កំ វណ្ណារ៉ា)*

*អត្ថបទដោយ៖ ម៉ង់ រ៉ាលី*




រូបលេខ២៖ ប្លង់ប្រាសាទបាគងដែលបង្ហាញតួប៉មឥដ្ឋចំនួន៨ជុំវិញ (ប្រភព៖ Thierry & Helen 2000)



រូបលេខ៣៖ ប្រាសាទបាគង (រូបថត៖ Rawson, 1999)



រូបលេខ៤៖ ក្រដាសផ្ដាមសិលាចារឹកបាគង K.826 ខេត្តសៀមរាប (ផ្ដិតដោយ៖ កំ វណ្ណារ៉ា)

អរិយធម៌ខ្មែរ
KHMER CIVILIZATION



រូបលេខ៥៖ ថ្មបញ្ចុះក្រោមគ្រឹះប្រាសាទរកឃើញនៅប្រាសាទអារាមរោងចិន ស.វ.ទី៩ (រូបថត៖ EFEO, 1930)



រូបលេខ៦៖ ប្រាសាទរាងប្រាំបីជ្រុងនៅក្រុមប្រាសាទយាយព័ន្ធ សំបូរព្រៃគុក តួប៉ម S10

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៧៖ ជើងទម្រប្រាំបីជ្រុងដាក់នៅខាងមុខប្រាសាទរាងប្រាំបីជ្រុង
នៅក្រុមប្រាសាទសំបូរឬក្រុមខាងជើង តំបន់សំបូរព្រៃគុក តួប៉ម N7

អត្ថបទដោយ៖ ម៉ង់ រ៉ាលី